# គ្មានឈ្មោះ
## ដោយ  យឹម ម៉ាលីន

រហូតមកដល់បច្ចុប្បន្ននេះ ការងាររបស់ យឹម ម៉ាលីន បានផ្តោតលើអនុស្សាវរីយកាលពីកុមារភាពរបស់គាត់ ដែលធំទ្បើងឆ្លងកាត់សង្គ្រាមស៊ីវិល។ ដោយយកការស្រមើស្រមៃមកបង្កើតទ្បើងវិញនូវភាពផុយស្រួយនៃជីវិតកាលពីកុមារ និងការប្រើប្រាស់សម្ភារៈប្រកបដោយជំនាញនិងមហិច្ឆតារបស់គាត់ រួមជាមួយនឹងភាពមិនច្បាស់លាស់និងភាពតានតឹងនៅក្នុងស្នាដៃ  បានធ្វើអោយយើងមានអារម្មណ៍មិនសុខស្រួល។ តាំងពីគំនូរខ្មៅដៃលើក្រដាស រហូតដល់ចម្លាក់ដ៏ស្មុគស្មាញនិងលំអិតជាមួយដីឥដ្ឋ រឺក៏ក្រណាត់ប៉ាក់ ម៉ាលីនតែងតែសួរអោយយើងធ្វើការផ្លាស់ប្តូរ។

*គ្មានឈ្មោះ* បន្ថែមពីលើគុណតម្លៃទាំងនេះ ដោយប្រើប្រាស់វីដេអូនិងសំលេង ហើយត្រទ្បប់មកពិភាក្សាអំពីបញ្ហាទីនេះ ឥទ្បូវនេះ។ ក្នុងនាមទើបជាម្តាយម្នាក់ ម៉ាលីនពិនិត្យលើលក្ខខណ្ឌបរិយាកាសដែលគាត់និងបីបាច់កូនរបស់គាត់ ជាពិសេសក្នុងខណៈពេលដែលយើងទាំងអស់គ្នាប្រឈមមុខនឹងកម្លាំងបំផ្លិចបំផ្លាញដ៏សកម្មនៃធម្មជាតិ។ នៅក្នុងពិព័រណ៍ *គ្មានឈ្មោះ* ម៉ាលីនអំពាវនាវអោយមានការពិចារណាដោយមនសិការអំពីការជាប់ទាក់ទងគ្នានៅក្នុងពិភពផែនដីនេះ ដោយផ្គូផ្គងនិមិត្តសញ្ញាសកលនៃកំណើតនិងជីវិតនៅក្នុងវដ្តនៃការវិនាសតាមធម្មជាតិ ជាមួយនឹងការគ្រប់គ្រងបង្កើតទ្បើងវិញ។

ដើរចូលមកក្នុងវិចិត្រសាល ពិព័រណ៍ *គ្មានឈ្មោះ* ហាក់ដូចជាកោះនៃកូនចក្រវាលមួយ។ ស្នាដៃតម្លើងនេះគឺមានការប្រែប្រួលជាប់ជានិច្ច ទៅតាមពេលវេលា និងទីតាំង។ នៅចំកណ្តាល មានដុំទឹកដោះគោកកមួយដុំចងព្យួរពីពិតាន ហើយនៅលើដុំទឹកដោះគោនោះគឺមានបញ្ចាំងរូបវីដេអូនៃស៊ុតកំពុងដុតនៅក្នុងឆ្នាំងរហូតដល់ផ្ទុះនិងបំផ្លាញអស់ ហាក់ដូចជាព្រឹត្តិការណ៍នៃការចាប់កំណើតនៃចក្រវាល។ បន្ទប់នៃវិចិត្រសាលដែលទទេ បានបន្លឺបំពងដោយសំលេងភ្លើងដុតនិងសំលេងផ្ទុះ ខណៈពេលដែលសំលេងមួយទៀតបានបន្លឺចេញដោយសារកម្តៅនៃការបញ្ចាំងវីដេអូដែលធ្វើអោយដុំទឹកដោះគោកករលាយ។ ពេលទឹកដោះគោរលាយស្រក់មកលើប្រអប់ខ្មៅដែលមានផ្ទាំងលោហៈនៅចំកណ្តាល សំលេងដូចគោះស្គរលាន់បន្ថែមនៅក្នុងបន្ទប់ ហាក់ដូចជាសំលេងចង្វាក់បេះដូងដែលកាន់តែញាប់ទៅៗរហូតដល់ឈប់ទាំងស្រុង។ ពេលដុំទឹកដោះគោថ្មីមួយត្រូវបានដាក់ ដំណើរការនេះចាប់ផ្តើមសារជាថ្មី។

ស្នាដៃនេះមានឈ្មោះថា *គ្មានឈ្មោះ* ដោយខ្វះអត្តសញ្ញាណច្បាស់លាស់ រឺក៏អំនះអំនាងកំនត់មួយ ដែលនេះធ្វើអោយលោកធាតុវិទ្យារបស់ ម៉ាលីន សង្កត់ធ្ងន់លើវដ្តនៃចក្រវាលដែលជារបស់យើងទាំងអស់គ្នា។ ភាពប្រែប្រួលនៃវត្ថុដោយឃើញច្បាស់ៗ តាមរយៈដំណើរការសារចុះសារទ្បើងនៅក្នុងទម្រង់មូលៗដែលឆ្លងឆ្លើយគ្នានេះ ស្នាដៃតម្លើងរបស់ម៉ាលីនអញ្ជើញទស្សនិកជនអោយដើរទស្សនានៅជុំវិញវា ហាក់ដូចជាការធ្វើដំណើរនៅលើរង្វង់គោចរ។ ស្នាដៃនេះមានលក្ខណៈអាថ៌កំបាំង តែក៏មានការបង្ហាញដោយចំៗនិងច្បាស់។

ពិព័រណ៍ *គ្មានឈ្មោះ* ធ្វើទ្បើងក្រោមកិច្ចសហការជាមួយមហោស្រពសិល្បៈយុវជនខ្មែរ និងរៀបចំទ្បើងដោយ វុធ លីណូ។

**អំពីសិល្បករ**

យឹម ម៉ាលីន កើតនៅឆ្នាំ ១៩៨២ នៅខេត្តបាត់ដំបង និងបានបញ្ចប់ការសិក្សាពីសាលាហ្វារពន្លឺសិល្បៈនៅឆ្នាំ ២០០៣។ គាត់បានទទួលបរិញ្ញាបត្រផ្នែកសិល្បៈសូនរូបពីសាលាវិចិត្រសិល្បៈនៃទីក្រុងកង់ (Caen la Mer) ប្រទេសបារាំងនៅឆ្នាំ ២០១០។ ពិព័រណ៍ជាក្រុមរបស់គាត់រួមមាន *ប្រាំពី* នៅសណ្ឋាគារដឺទ្បាប៉េ សៀមរាប (២០១២) និងឥទ្បូវនេះ *ដំណើរថ្មី* នៅអង្គការសិល្បៈខ្មែរអមតៈ ភ្នំពេញ។ ពិព័រណ៍ទោលរបស់គាត់មាន *សរសៃសូត្រ* នៅវិចិត្រសាល Insider សណ្ឋាគារអាំងទែរកុងទីណង់តាល់ ភ្នំពេញ (២០១២) និង *ការចងចាំ* នៅស-សបាសាក់ (២០១១)។

# No Name
## Yim Maline

Until now, Yim Maline's practice has activated memories specific to her childhood growing up amidst civil war. Using fantasy to reconstruct fragility, her ambitious and skillful use of materials challenges our perception, while an inherent vein of uncertainty and tension challenges our comfort. From her meticulous graphite-on-paper drawings to her intricate sculptures in clay or lace, Yim asks us to adjust.

*No Name* extends these qualities through video and sound, and turns to the here and now. Newly a mother, Yim considers the conditions in which she will raise her daughter, especially as we together face the assertive and destructive force of nature. In *No Name*, Yim calls for a conscious consideration of interconnectivity, pairing universal symbols of birth and life in a cycle of 'natural' destruction and controlled regeneration.

Entering the gallery, *No Name* is like a minimal island-universe. Dependent on time and space, the installation is in a constant state of flux. At its center is a suspended frozen disk of milk, onto which a looped video is projected: the image is an egg burning until annihilation, like a micro big bang. The otherwise empty gallery space is filled with the sound of searing flames and explosion, while a second channel of sound is activated by the heat of the projection which forces the milk to melt. As the milk drips away onto a black and mirrored acoustic platform below, a troubling drum is layered into the space, a heartbeat that quickens over the hours until it stops completely. As a new disk is installed, the process repeats.

The work is named *No Name*, and as such lacks a specific identity or fixed referent: Yim's cosmology is emphatically cyclic and belongs to us all. A literal transformation of matter through a repetitive process embodied in a series of interacting circular forms, Yim's installation invites the audience to circumnavigate it. The work is as acute as it is mysterious.

*No Name* is held in collaboration with the Cambodian Youth Arts Festival, and is curated by Vuth Lyno.

**About the Artist**
Yim Maline was born in 1982 in Battambang, and is a graduate of Phare Ponleu Selpak art school (2003). She holds a BFA in Fine Art, École Supérieure des Beaux-arts de Caen la Mer, France (2010). Yim's group exhibitions include *Seven* at Hotel de la Paix Arts Lounge, Siem Reap (2012) and currently *Dom-naer Thmey* at Cambodian Living Arts, Phnom Penh. Yim's solo exhibitions include *Silk Threads* at Insider Gallery, InterContinental Hotel, Phnom Penh (2012) and *Remember* at SA SA BASSAC (2011).

ស-សបាសាក់ SA SA BASSAC
#18 2nd Floor, Sothearos Boulevard
PO Box 2181 Phnom Penh 3, Cambodia
+855 (0)17 774 864
www.sasabassac.com

# គ្មានឈ្មោះ
## ដោយ  យឹម ម៉ាលីន

# No Name
## Yim Maline

15 - 18 November 2012



Yim Maline, *No Name* detail, 2012, mixed media installation